# គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា
## សេចក្តីសង្ខេបស្តីពីក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់

1. សេចក្តីសង្ខេបនេះ បានលើកយកចំណុចសំខាន់ត្រូវរៀបចំក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ និងផែនការពិស្តារត្រូវបានពិពណ៌នានៅក្នុងអត្ថបទនិងឧបសម្ព័ន្ធនៃក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់

2. ក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់នេះត្រូវបានរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់សមាសភាពទី២ នៃគម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា (CRCIP) ដោយមានការគាំទ្រពីទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិ អនុលោមតាមគោលការណ៍អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្របខ័ណ្ឌនេះ ជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន ដែលនឹងត្រូវយកមកប្រើប្រាស់ចំពោះគម្រោងវិនិយោគ ក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោក សំដៅផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជាក្នុងការដោះស្រាយផលប៉ះពាល់។ ឯកសារនេះ ត្រូវបានរៀបចំស្របតាមស្តង់ដានៃនីតិវិធីប្រតិបត្តិការដោះស្រាយផលប៉ះពាល់របស់រាជរដ្ឋាភិបាលកម្ពុជា និងមានសង្គតិភាពជាមួយឯកសារក្របខ័ណ្ឌសង្គម និងបរិស្ថានរបស់ធនាគារពិភពលោក

3. សេចក្តីព្រាងនេះ ត្រូវបានចាត់ទុកជាឯកសារដែលអាចធ្វើបច្ចុប្បន្នភាពបាន ស្របទៅតាមស្ថានភាព និងសកម្មភាពជាក់ស្តែងរបស់គម្រោង ដោយផែនការស្តីពីក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់និងត្រូវបានរៀបចំលម្អិតក្រោយពេលកិច្ចពិគ្រោះយោបល់ជាមួយអ្នកទទួលរងផលប៉ះពាល់ពីគម្រោង និងជាមួយធនាគារពិភពលោក

4. គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា នឹងធ្វើការកែលម្អផ្លូវពីកម្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ សំដៅធ្វើឲ្យផ្លូវមានភាពធន់ ឬបន្សាំនឹងការបម្រែបម្រួលអាកាសធាតុ ស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ មានប្រវែង ២៥០ គីឡូម៉ែត្រ

5. ដំណើការអនុវត្តគម្រោង រំពឹងថានិងមិនមានផលប៉ះពាល់ដល់បញ្ហាដីធ្លី ឬទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋលើការកែលម្អផ្លូវ ករណីបើមានការប៉ះពាល់ ហើយមិនការផ្តល់ ឬបរិច្ចាគដោយស្ម័គ្រចិត្តពីប្រជាពលរដ្ឋទេ នោះគោលការណ៍ដោះស្រាយផលប៉ះពាល់ត្រូវបានអនុវត្ត

6. ព្រះរាជាណាចក្រកម្ពុជា ច្បាប់អស្សាមិករណ៍ (២០១០) គឺជាឯកសារច្បាប់ដ៏សំខាន់មួយដែលផ្តោតលើការដោះស្រាយផលប៉ះពាល់។មាត្រាទី៣៖ គម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ រាជរដ្ឋាភិបាលកម្ពុជាបានចេញនូវស្តង់ដានីតិវិធីប្រតិបត្តិ (SOP) នៅឆ្នាំ២០១៨ ដាក់ឲ្យប្រើប្រាស់សម្រាប់ជាយន្តការក្នុងការដោះស្រាយផលប៉ះពាល់។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលខុសត្រូវក្នុងការផ្តល់គោលការណ៍ណែនាំដល់អ្នកប្រើប្រើប្រាស់ឯកសារ SOP ដោយគម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា ផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក

ត្រូវអនុវត្តតាមខ្លឹមារនៃការណែនាំដូចមានចែងក្នុងSOP។ ឯកសារក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ រៀបចំឡើងដោយអនុលោមតាមស្តង់ដាទី៥ ស្តីពីសង្គម និងបរិស្ថានរបស់ធនាគារពិភពលោកលើការដោះស្រាយផលប៉ះពាល់ពេលអនុវត្តគម្រោង។មានចំណុចខ្វះចន្លោះតិចតួច រវាងស្តង់ដានីតិវិធីប្រតិបត្តិ និងស្តង់ដាទី៥ របស់ធនាគារពិភពលោក ត្រង់ថាមិនមានការបរិយាយអំពីគោលការណ៍ក្នុងការស្ម័គ្រចិត្តបរិច្ចាគពីសំណាក់អ្នកពាក់ព័ន្ធ ឬអ្នកទទួលរងផលប៉ះពាល់ គឺមានតែគោលការណ៍ចំពោះអ្នកដែលមិនស្ម័គ្រចិត្តបរិច្ចាគ ត្រូវដោះស្រាយផលប៉ះពាល់ ដូចនេះ ឯកសារក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់នឹងការរៀបរាប់អំពីដំណើការ និងនីតិវិធីសម្រាប់ការស្ម័គ្រចិត្តបរិច្ចាគនិងមានសង្គតិភាពជាមួយស្តង់ដារបស់ធនាគារពិភពលោក

7. គម្រោងមាននីតិវិធីគ្រប់គ្រងការដោះស្រាយផលប៉ះពាល់ដោយអនុលោមតាមឋានានុក្រមក្នុងការកាត់បន្ថយផលប៉ះពាល់ និងហានិភ័យ ដូចខាងក្រោម៖
   ក. កែសម្រួលគ្រោងប្លង់ដើម្បីបញ្ចៀសផលប៉ះពាល់លើដី និងទ្រព្យសម្បត្តិ
   ខ. ធ្វើឲ្យការប៉ះពាល់មានកម្រិតអតិប្បរមា បើសិនជាមានករណីដែលមិនអាចជៀសបាន
   គ. ពិគ្រោះជាមួយពលរដ្ឋដែលរងការប៉ះពាល់ ដើម្បីផ្តល់ជម្រើស និងលើកទឹកចិត្តដល់ពួកគាត់ធ្វើការបរិច្ចាគដោយស្ម័គ្រចិត្ត ជាងការផ្តល់សំណង ករណីលក្ខណៈវិនិច្ឆ័យដែលរៀបរាប់នៅក្នុងក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ត្រូវបានអនុវត្ត
   ឃ. ចំពោះអ្នកមិនព្រមបរិច្ចាគដោយស្ម័គ្រចិត្ត ឬមិនសមស្របនឹងលក្ខណៈវិនិច្ឆ័យ(i)ផ្តល់សំណងទៅតាមតម្លៃទីផ្សារ/តម្លៃការផ្លាស់ប្តូរទីតាំងដី-ទ្រព្យដែលបាត់បង់ ឬប្តូរដីជំនួស សម្រាប់ដីដែលបានបាត់បង់ (ii) ការផ្តល់សំណង នឹងត្រូវធ្វើឡើងមុនពេលចាប់ផ្តើមការងារសាងសង់ ហើយផែនការដោះស្រាយផលប៉ះពាល់ត្រូវបានផ្សព្វផ្សាយដើម្បីជូនដំណឹងជាសាធារណៈអំពីដំណើរការនៃការដោះស្រាយបណ្តឹងតវ៉ា

8. ឯកសារនេះ មានវិសាលភាពគ្របដណ្តប់លើ (i) ដី/ទ្រព្យដែលបរិច្ចាគដោយស្ម័គ្រចិត្ត (ii) ដី/ទ្រព្យដែលបរិច្ចាគដោយមិនស្ម័គ្រចិត្ត។ ការបរិច្ចាគដោយស្ម័គ្រចិត្ត ត្រូវធ្វើឡើងដោយមានការជូនដំណឹង និងពន្យល់ច្បាស់លាស់ ព្រមទាំងរៀបចំចងក្រងជាឯកសារត្រឹមត្រូវ ដោយប្រជាពលរដ្ឋត្រូវបានជ្រាបថាពួកគាត់ដែលកំពុងរស់នៅតាមខ្សែផ្លូវគម្រោង នឹងត្រូវទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ ធំធេងពីគម្រោង បើប្រៀបធៀបការបរិច្ចាគបន្តិចបន្តួច ដូចជា ផ្លូវចូលផ្ទះ ឬរបងផ្ទះរបស់ពួកគាត់។ ករណីការបរិច្ចាគដោយមិនស្ម័គ្រចិត្ត នឹងមានការរៀបចំពិស្តារនូវរចនាសម្ព័ន្ធស្ថាប័នទទួលខុសត្រូវ និងតួនាទីភារកិច្ច ការពិគ្រោះយោបល់ ការផ្សព្វផ្សាយអំពីគម្រោង និងយន្តការផ្តល់សំណង ព្រមទាំងការត្រួតពិនិត្យវាយតម្លៃ

9. ក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ ត្រូវអនុវត្តចំពោះការផ្លាស់ប្តូរទីលំនៅបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ដូចមានចែងក្នុងឯកសារស្តង់នីតិវិធីប្រតិបត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលការណ៍របស់ធនាគាពិភពលោក។ គ្រួសារដែលរងផលប៉ះពាល់ ដែលមានដី/ទ្រព្យនៅលើខ្សែផ្លូវត្រូវកែលម្អ មុនពេលនៃកាលបរិច្ឆេទដែលមានសុពលភាព (Cut-off date) គឺមានសិទ្ធិអាចទទួលយកសំណងបានបើសិន

ពួកគាត់មានលក្ខណៈគ្រប់គ្រាន់ខាងទិដ្ឋភាពច្បាប់ ដែលក្នុខណ្ឌ៍អាចទទួលយកសំណងបាន លុះត្រាតែបញ្ហារបស់ពួកគាត់ត្រូវបានលើកមកពិភាក្សានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ នៅពេលដែលខ្សែផ្លូវ និងកន្លែងដែលត្រូវបានប៉ះពាល់បានកំណត់ដោយគម្រោង តាមរយៈការផ្សព្វផ្សាយនៅតាមសាលាឃុំ/សង្កាត់ ផ្ទាំងព័ត៌មានសាធារណៈ ឬតាមវត្តអារាមជាដើម។ ករណីបើមានអ្នកទន្ទ្រានឬកាន់កាប់ទីតាំងដី/ទ្រព្យដែលឯកភាជាមួយគម្រោងក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំពិគ្រោះយោបល់នឹងមិនមានសិទ្ធិទទួលបានសំណង ឬជំនួយផ្សេងៗឡើយ

10. ក្របខណ្ឌដោះស្រាយផលប៉ះពាល់ បានបញ្ជាក់អំពីយន្តការដោះស្រាយបណ្ដឹងតវ៉ា ដែលត្រូវបានរៀបចំឡើងនៅតាមតំបន់ ដោយប្រើប្រាស់រចនាសម្ព័ន្ធមានស្រាប់ ក្នុងគោលបំណងដើម្បីទទួលព័ត៌មានត្រឡប់ កត់ត្រា វាយតម្លៃ និងសម្របសម្រួលដោះស្រាយការតវ៉ានានាដែលអាចកើតមានឡើងពីសំណាក់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ លើដំណើរការនៃការអនុវត្តគម្រោងកែលម្អបណ្ដាញផ្លូវថ្នល់នៅកម្ពុជា។ ឯកសារក្របខ័ណ្ឌនេះបានរៀបរាប់អំពីនីតិវិធី និងដំណើការក្នុងការពិគ្រោះយោបល់ និងផ្សព្វផ្សាយព័ត៌មាន ក្នុងករណីមានការបរិច្ចាគដោយស្ម័គ្រចិត្ត ហើយឯកសារស្ដីពីក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់នេះត្រូវបានប្រជុំពិគ្រោះយោបល់នៅថ្នាក់ជាតិជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ នាថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២០ និងត្រូវបានផ្សព្វផ្សាយជាសាធារណៈមុនការវាយតម្លៃគម្រោងរបស់ធនាគារពិភពលោកក្នុងការផ្ដល់ហិរញ្ញប្បទាន សម្រាប់ការអនុវត្តគម្រោងកែលម្អបណ្ដាញផ្លូវថ្នល់នៅកម្ពុជា។